# សេចក្តីថ្លែងការណ៍

**គណបក្ស ភ្លើងទៀន** សម្តែងការសោកស្តាយចំពោះក្រសួងមហាផ្ទៃដែលបដិសេធមិនទទួលលិខិតស្នើសុំជួប **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ដើម្បីជួយផ្តល់ដំណោះស្រាយពាក់ព័ន្ធឯកសារលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយ នៅក្រសួងមហាផ្ទៃរបស់គណបក្ស ភ្លើងទៀន។

នៅរសៀលថ្ងៃទី០២ ខែសីហា ឆ្នាំ២០២៣នេះ **គណបក្ស ភ្លើងទៀន** បានដាក់លិខិតទៅក្រសួងមហាផ្ទៃស្តីពីសំណើសុំជួប **សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** ដើម្បីជួយផ្តល់ដំណោះស្រាយពាក់ព័ន្ធឯកសារលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយ នៅក្រសួងមហាផ្ទៃ របស់គណបក្ស ភ្លើងទៀន ប៉ុន្តែត្រូវបានក្រសួងមហាផ្ទៃបដិសេធមិនទទួលលិខិតរបស់គណបក្ស ភ្លើងទៀន ដោយប្រាប់ឲ្យរង់ចាំរហូតដល់មានរដ្ឋាភិបាលថ្មី។

នេះមិនមែនជាលើកទី១ទេ ដែលក្រសួងមហាផ្ទៃបដិសេធមិនទទួលលិខិតរបស់គណបក្ស ភ្លើងទៀន ពាក់ព័ន្ធការរកដំណោះស្រាយជុំវិញឯកសារលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយ នៅក្រសួងមហាផ្ទៃ របស់គណបក្ស ភ្លើងទៀន។ កាលពីថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣ គណបក្ស ភ្លើងទៀន បានដាក់លិខិត ដូចគ្នានេះទៅក្រសួងមហាផ្ទៃ តែត្រូវក្រសួងមហាផ្ទៃបដិសេធមិនទទួលយក ដោយស្នើសុំឲ្យគណបក្ស ភ្លើងទៀន ដាក់លិខិតនៅក្រោយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៣។

សូមបញ្ជាក់ថា **គណបក្ស ភ្លើងទៀន** បានបាត់ច្បាប់ដើមនៃប្រកាសលេខ ១៩៣ ប្រក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ របស់ក្រសួងមហាផ្ទៃ ស្តីពីការចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយ ក្នុងអំឡុងឆ្នាំ២០១៧ នៅពេលដែលទីស្នាក់ការកណ្តាលគណបក្ស ភ្លើងទៀន ដែលស្ថិតនៅខាងក្រោមទីស្នាក់ការអតីតគណបក្សសង្គ្រោះជាតិ ត្រូវបានបិទដោយអំណាចសាលដីការបស់តុលាការកំពូល ហើយនៅពេលនោះ គណបក្ស ភ្លើងទៀន បានដាក់លិខិតស្នើសុំទៅសាលាដំបូងរាជធានីភ្នំពេញ និងសាលាឧទ្ធរណ៍ ដើម្បីប្រើប្រាស់ទីស្នាក់ការ និងប្រមូលឯកសារនានារបស់គណបក្សពីទីស្នាក់ការ




ផ្ទះលេខ ៣២០ ផ្លូវលេខ ១០ម៉ែត្រថ្មី បុរីពិភពថ្មី ភូមិបាយ៉ាប សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ
#320, Street 10m Thmey, Borey Piphob Thmey, Bayarb Village, Sangkat Phnom Penh Thmey, Khan Sen Sok, Phnom Penh
Website: www.candlelightparty.org / Email: info@candlelightparty.org

ប៉ុន្តែមិនបានទទួលការអនុញ្ញាតពីសាលាដំបូងរាជធានីភ្នំពេញ និងសាលាឧទ្ធរណ៍ឡើយ ជាហេតុធ្វើឲ្យឯកសារមួយចំនួនរបស់គណបក្ស រួមទាំងច្បាប់ដើមនៃប្រកាសលេខ ១៩៣ ប្រក ផង ត្រូវបានបាត់បង់។

**គណបក្ស ភ្លើងទៀន** បានខិតខំប្រឹងប្រែងក្នុងការរកដំណោះស្រាយពាក់ព័ន្ធប្រកាសលេខ ១៩៣ ប្រក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ១៩៩៨ ដោយធ្វើទំនាក់ទំនងជាមួយក្រសួងមហាផ្ទៃ តាំងពីដើមខែមេសា ឆ្នាំ២០២៣ មុនដំណាក់កាលនៃការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះសម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣ ប៉ុន្តែរហូតមកដល់ពេលនេះ ក្រសួងមហាផ្ទៃ ដែលជាស្ថាប័នមានសមត្ថកិច្ចក្នុងការចេញប្រកាសស្តីពីការចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយ នៅពុំទាន់ផ្តល់ដំណោះស្រាយអ្វីដល់គណបក្ស ភ្លើងទៀន ក្រៅតែពីចេញលិខិតបញ្ជាក់លេខ ០៤៣ ប ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០២៣ ដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) បដិសេធមិនទទួលស្គាល់ និងមិនអនុញ្ញាតឲ្យគណបក្ស ភ្លើងទៀន ចូលរួមក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ នីតិកាលទី៧ ឆ្នាំ២០២៣នោះឡើយ។

**គណបក្ស ភ្លើងទៀន** នឹងបន្តកិច្ចខិតខំប្រឹងប្រែងក្នុងការរកដំណោះស្រាយ ជាមួយក្រសួងមហាផ្ទៃ ហើយសង្ឃឹមថាក្រសួងមហាផ្ទៃនៃរាជរដ្ឋាភិបាលអាណត្តិថ្មី នឹងជួយផ្តល់ដំណោះស្រាយពាក់ព័ន្ធឯកសារលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយ នៅក្រសួងមហាផ្ទៃ របស់គណបក្សភ្លើងទៀន ដើម្បីគណបក្ស ភ្លើងទៀន យកមកប្រើប្រាស់ក្នុងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះសម្រាប់ការបោះឆ្នោតទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិជាបន្តបន្ទាប់នៅពេលខាងមុខ៕

**ថ្ងៃព្រហស្បតិ៍ ២ រោច ខែទុតិយាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស ២៥៦៧**

**រាជធានីភ្នំពេញ, ថ្ងៃទី០៣ ខែសីហា ឆ្នាំ២០២៣**

**គណបក្សភ្លើងទៀន**

**ព័ត៌មានបន្ថែម សូមទាក់ទង :**

**- ០៧៨ ៤៤ ៦៥ ៨៨**